





ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល

# ការជួយអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ាឱ្យទទួលបានជំនួយនៅពេលដែលត្រូវការបំផុត។

EDD

DE 2511D/CA Rev. 23 (5-25) (**INTERNET**)



## តើខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់អត្ថប្រយោជន៍ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួលទេ?

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់អត្ថប្រយោជន៍ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល អ្នកត្រូវតែ៖

- សម្រាកពីការងារ ដើម្បីជួយថែទាំសមាជិកគ្រួសារដែលមានជំងឺធ្ងន់ធ្ងរ ដើម្បីបង្កើតភាពស្និទ្ធស្នាលជាមួយកូនដែលទើបតែកើតថ្មីៗ ឬចូលរួមនៅក្នុងព្រឹត្តិការណ៍យោធាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- មានការធានារ៉ាប់រងតាមរយៈការធានារ៉ាប់រងពិការភាពរបស់រដ្ឋ ឬតាមរយៈផែនការស្ម័គ្រចិត្តជំនួសឱ្យការធានារ៉ាប់រងពិការភាពរបស់រដ្ឋ។
- រកបានប្រាក់ចំណូលយ៉ាងតិចចំនួន $300 ក្នុងរយៈពេល 5 ទៅ 18 ខែកន្លងមក។
- ដាក់ពាក្យទាមទារសំណងរបស់អ្នកមិនឱ្យលើសពី 41 ថ្ងៃបន្ទាប់ពីអ្នកចាប់ផ្តើមច្បាប់ឈប់សម្រាកគ្រួសាររបស់អ្នក។ សូមកុំដាក់ពាក្យទាមទារសំណងមុនថ្ងៃដំបូងនៃការឈប់សម្រាករបស់អ្នក។

## តើចំនួនអត្ថប្រយោជន៍ត្រូវបានគណនាដោយរបៀបណា?

អត្ថប្រយោជន៍គឺមានចំនួនពី 70 ទៅ 90 ភាគរយនៃប្រាក់ចំណូលប្រចាំត្រីមាសខ្ពស់បំផុតរបស់អ្នក កាលពី 5 ទៅ 18 ខែមុនពេលការទាមទារសំណងរបស់អ្នកចាប់ផ្តើម។

សូមធ្វើការប៉ាន់ប្រមាណពីចំនួនអត្ថប្រយោជន៍របស់អ្នក តាម Disability Insurance and Paid Family Leave Calculator។



# តើការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួលផ្តល់ការការពារដល់ការងារដែរឬទេ?

ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួលមិនផ្តល់ការការពារដល់ការងារទេ។ ការការពារចំពោះការងារអាចត្រូវបានផ្តល់ឱ្យប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមច្បាប់ផ្សេងៗ៖

- Family and Medical Leave Act សហព័ន្ធ។
- ច្បាប់ស្តីពីសិទ្ធិគ្រួសាររដ្ឋកាលីហ្វ័រញ៉ា។ Civil Rights Department។

សូមជូនដំណឹងដល់និយោជករបស់អ្នកអំពីផែនការឈប់សម្រាករបស់អ្នក និងហេតុផលនៃការឈប់សម្រាកស្របតាមគោលនយោបាយក្រុមហ៊ុនរបស់អ្នក។

# តើខ្ញុំដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ដោយរបៀបណាដែរ?

អ្នកអាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួលនៅ myEDD។

ដើម្បីដាក់ពាក្យទាមទារសំណងរបស់អ្នកតាមសំបុត្រ អ្នកត្រូវបំពេញ និងផ្ញើ*ទម្រង់បែបបទអត្ថប្រយោជន៍ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល (PFL)* (DE 2501F)។ អ្នកអាចសិក្សាស្វែងយល់បន្ថែមនៅ File a Paid Family Leave Claim by Mail។

# ការទាមទារសំណងសម្រាប់ការថែទាំ

ផ្តល់វិញ្ញាបនបត្រវេជ្ជសាស្ត្រ (សំបុត្រពេទ្យ) សម្រាប់សមាជិកគ្រួសារដែលមានជំងឺធ្ងន់ធ្ងររបស់អ្នក ដែលត្រូវការការថែទាំពីអ្នក។ វិញ្ញាបនបត្រ (សំបុត្រពេទ្យ) នេះត្រូវតែចេញដោយអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាបណ្ណរបស់ពួកគេ។ អ្នកត្រូវតែផ្តល់ព័ត៌មានពីសមាជិកគ្រួសារដែលអ្នកកំពុងមើលថែទាំ និងហត្ថលេខារបស់ពួកគាត់ផងដែរ។

# ការទាមទារសំណងសម្រាប់ការបង្កើតភាពស្និទ្ធស្នាល

ផ្តល់ឯកសារដែលបញ្ជាក់ពីទំនាក់ទំនងរបស់អ្នកជាមួយនឹងកូនរបស់អ្នក។ ឯកសារនេះអាចជាច្បាប់ចម្លងសំបុត្រកំណើតកូនរបស់អ្នក កិច្ចព្រមព្រៀងសុំកូនយកទៅចិញ្ចឹម ឬកំណត់ត្រាឱ្យកូនគេយកទៅចិញ្ចឹមបណ្តោះអាសន្ន។

ប្រសិនបើអ្នកកំពុងទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងពិការភាពទាក់ទងនឹងការមានផ្ទៃពោះ អ្នកមិនចាំបាច់ស្នើសុំទម្រង់បែបបទពាក្យស្នើសុំទាមទារសំណងសម្រាប់ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួលទេ។ ទម្រង់បែបបទដាក់ពាក្យស្នើសុំសម្រាប់ការបង្កើតភាពស្និទ្ធស្នាលជាមួយកូននឹងត្រូវបានផ្ញើឱ្យអ្នកតាមរយៈគណនី myEDD របស់អ្នក ឬតាមសំបុត្រ នៅពេលដែលពាក្យស្នើសុំពិការភាពដែលទាក់ទងនឹងការមានផ្ទៃពោះរបស់អ្នកបានបញ្ចប់។



## ការទាមទារសំណងជំនួយយោធា

ការទាមទារសំណងជំនួយយោធាត្រូវការមានឯកសារគាំទ្រចំនួនពីរប្រភេទ។ វាអាចជាភស្តុតាងនៃកាតព្វកិច្ចសកម្មដែលត្រូវបានធានារ៉ាប់រង ឬការអំពាវនាវឱ្យបំពេញកាតព្វកិច្ចសកម្មដែលត្រូវបានធានារ៉ាប់រង និងឯកសារនៃព្រឹត្តិការណ៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ផែនការស្ម័គ្រចិត្ត

ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងដោយផែនការស្ម័គ្រចិត្ត សូមទាក់ទងទៅនិយោជករបស់អ្នកសម្រាប់ព័ត៌មានអំពីការធានារ៉ាប់រងរបស់អ្នក និងការណែនាំពីរបៀបដាក់ពាក្យស្នើសុំអត្ថប្រយោជន៍។

DE 2511D/CA Rev. 23 (5-25) (**INTERNET**)

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើការទាមទារសំណងរបស់ខ្ញុំត្រូវបានបដិសេធ?

ប្រសិនបើការទាមទារសំណងរបស់ខ្ញុំត្រូវបានបដិសេធ អ្នកមានសិទ្ធិ៖

- ដឹងពីហេតុផលនៃការបដិសេធនោះ។
- ការសម្រេចចិត្តលើបណ្តឹងឧទ្ធរណ៍អំពីសិទ្ធិទទួលបានអត្ថប្រយោជន៍របស់អ្នក។ សូមចូលទៅកាន Appeals សម្រាប់ព័ត៌មានបន្ថែម។

គ្រប់ព័ត៌មានទាំងអស់អំពីការទាមទារសំណងនឹងត្រូវរក្សាជាការសម្ងាត់ លើកលែងតែយកទៅប្រើក្នុងគោលបំណងដែលច្បាប់អនុញ្ញាតតែប៉ុណ្ណោះ។

## អំពីការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល

កម្មវិធីឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល ត្រូវបានបង្កើតឡើងដើម្បីជួយគាំទ្រដល់បុគ្គលដែលត្រូវការជំនួយបំផុតនៅក្នុងជីវិតរបស់ពួកគេ។ ដោយផ្តល់អត្ថប្រយោជន៍ដើម្បីជួយថែទាំសមាជិកគ្រួសារដែលមានជំងឺធ្ងន់ធ្ងរ ដើម្បីបង្កើតភាពស្និទ្ធស្នាលជាមួយកូនដែលទើបតែកើតថ្មីៗ ឬចូលរួមនៅក្នុងព្រឹត្តិការណ៍យោធាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

# ការពិតអំពីការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល

- ផ្តល់អត្ថប្រយោជន៍ដើម្បីជំនួសប្រាក់ឈ្នួលមួយផ្នែកក្នុងរយៈពេលដល់ទៅប្រាំបីសប្តាហ៍។ ការឈប់សម្រាកមិនចាំបាច់ធ្វើឡើងទាំងអស់តែម្តងក្នុងពេលតែមួយទេ។
- ផ្តល់អត្ថប្រយោជន៍ឱ្យប្រហែលចំនួន 70 ទៅ 90 ភាគរយនៃប្រាក់ឈ្នួលប្រចាំសប្តាហ៍របស់អ្នក។
- ទទួលបានមូលនិធិតាមរយៈការកាត់ពន្ធធានារ៉ាប់រងពិការភាពរដ្ឋរបស់អ្នកដែលបានកត់ត្រាថា "CASDI" នៅលើបណ្ណបង់ប្រាក់ឈ្នួល ឬផែនការស្ម័គ្រចិត្តដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលបានបង់ក្នុងរយៈពេល 5 ទៅ 18 ខែកន្លងមក។
- ដើម្បីបង្កើតភាពស្និទ្ធស្នាលជាមួយកូនដែលទើបតែកើតថ្មីៗ ការឈប់សម្រាកអាចធ្វើឡើងនៅពេលណាក៏បានក្នុងរយៈពេល 12 ខែដំបូងនៃកូនដែលទើបតែចូលមកនៅក្នុងគ្រួសាររបស់អ្នក។
- ស្ថានភាពសញ្ជាតិ និងអន្តោប្រវេសន៍មិនប៉ះពាល់ដល់សិទ្ធិទទួលបានអត្ថប្រយោជន៍នេះទេ។





# ការឈប់សម្រាកគ្រួសារដោយមានប្រាក់ឈ្នួល

តែងតែមានវត្តមានជានិច្ចនៅពេលដែលជីវិតរបស់អ្នកត្រូវការជំនួយបំផុត។

## លេខទូរសព្ទ PFL

លេខទូរសព្ទឥតគិតថ្លៃរបស់យើងគឺ **1-877-238-4373**។ អ្នកអាចរកតំណាងបានចាប់ពីថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច លើកលែងតែថ្ងៃឈប់សម្រាក។ បន្ទាប់ពីមានសាររយៈពេលខ្លីចប់ទៅ អ្នកត្រូវតែជ្រើសរើសភាសា។

- សូមចុចលេខ 1 សម្រាប់ភាសាអង់គ្លេស
- សូមចុចលេខ 2 សម្រាប់ភាសាអេស្ប៉ាញ
- សូមចុចលេខ 3 សម្រាប់ភាសាផ្សេងៗទៀតទាំងអស់។ មានផ្តល់ជូនសេវាកម្មបកប្រែដោយឥតគិតថ្លៃ។

## លេខទូរសព្ទ TTY

លេខទូរសព្ទឥតគិតថ្លៃរបស់យើងគឺ **1-880-445-1312**។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ State Disability Insurance។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ Paid Family Leave